ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ០៥ ប្រកគ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ៤កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
# ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

នៅព្រឹកថ្ងៃសុក្រ ៤កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៨និង០០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

៣- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៣-២០២៥។

៤- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

៤.១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មនៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន។

៤.២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក) នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

៤.៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

ក្រោយពីបានស្តាប់របាយការណ៍ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងសម្រេចតាមរបៀបវារៈ ដែលមានលទ្ធផលនិងខ្លឹមសារសង្ខេបដូចខាងក្រោម៖

## ១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងដោយមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

ក. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២៣

សម្រាប់ឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ដែលធ្វើឱ្យ ផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់ ១៣១ ២៧៦ប៊ីលានរៀល សមមូលនឹងប្រមាណ ៣២ ២៩១លានដុល្លារអាម៉េរិក ស្របពេលដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៩២៤ដុល្លារអាម៉េរិក បើធៀបនឹង ១ ៧៨៥ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២២។ កំណើននេះ ត្រូវបានគាំទ្រដោយការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចសំខាន់ៗក្នុងឆ្នាំ២០២២ ដូចជាវិស័យឧស្សាហកម្មមានអត្រាកំណើន៩,២% (៩% ក្នុងឆ្នាំ២០២២) វិស័យសេវាកម្មមានអត្រាកំណើន ៦,៦% (៤,៣% ក្នុងឆ្នាំ២០២២) និងវិស័យកសិកម្មមានអត្រាកំណើន១,១% (០,៧% ក្នុងឆ្នាំ២០២២)។

នៅក្នុងឆ្នាំ២០២៣ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានរំពឹងថា កើនឡើងក្នុងរង្វង់ ២,៥%។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាម៉េរិកត្រូវបានប៉ាន់ស្មានថា នឹងនៅតែបន្តមានស្ថិរភាពក្នុងរង្វង់ ៤ ០៦៥រៀល ក្នុងមួយដុល្លារអាម៉េរិក។ ឱនភាពគណនីចរន្ត(រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថារួមតូចមកត្រឹម១៤,១% នៃ ផ.ស.ស.។ ដោយឡែក ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២២ ១៤៩លានដុល្លារអាម៉េរិក ដែលធានាការនាំចូលបាន៧,៦ខែ។

ចំពោះក្របខ័ណ្ឌថវិកាឆ្នាំ២០២៣ ចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងចំនួន ២៩ ៣១២ ប៊ីលានរៀល ត្រូវជា២២,៣៣% នៃ ផ.ស.ស. ដែលមានការកើនឡើង១៤,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។ ក្របខ័ណ្ឌថវិកាឆ្នាំ២០២៣ មានគោលដៅបង្កើនចំណូលចរន្តថវិកាជាតិឱ្យបានស្មើនឹង ២១,៤៦% នៃផ.ស.ស. ដែលមានការកើនឡើងចំនួន ១,២៧ពិន្ទុភាគរយ នៃ ផ.ស.ស. ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២ ពោលគឺនឹងសម្រេចបានខ្ពស់ជាងគោលដៅនៃការប្រមូលចំណូលចរន្តថវិកាជាតិ ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម ០,៣ពិន្ទុភាគរយ នៃ ផ.ស.ស. ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៣។

ខ. គម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣

ថវិកាឆ្នាំ២០២៣ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិ ឱ្យស្មើនឹង២០,៣៥% នៃ ផ.ស.ស. គឺស្មើនឹង ២៦ ៧០៩ប៊ីលានរៀល (ប្រមាណ ៦ ៥៧០លានដុល្លារអាម៉េរិក) ដែលកើនឡើង ១៣,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។ តាមគោលដៅនេះ ចំណូលចរន្តថ្នាក់ជាតិ ត្រូវសម្រេចឱ្យបានចំនួន ២៥ ៥៦៤ប៊ីលានរៀល (ប្រមាណ ៦ ២៨៨លានដុល្លារអាម៉េរិក) ត្រូវជា១៩,៤៧% នៃ ផ.ស.ស. គឺមានការកើនឡើង១៥,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។ ចំពោះ ចំណូលមូលធន ត្រូវបានគ្រោងចំនួន ៨ ៦០១ប៊ីលានរៀល (ប្រមាណ ២ ១១៥លានដុល្លារអាម៉េរិក) ត្រូវជា៦,៥៥% នៃ ផ.ស.ស. គឺកើនឡើង២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។

ថវិកាជាតិឆ្នាំ២០២៣ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយថវិកាថ្នាក់ជាតិសរុបស្ថិតក្នុងកម្រិតចំនួន ៣៦ ៦០៤ប៊ីលានរៀល (ប្រមាណ ៩ ០០៤លានដុល្លារអាម៉េរិក) ត្រូវជា២៧,៨៨% នៃ ផ.ស.ស. ដែលកើនឡើង១២,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។ ក្នុងនោះ ចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវបានកំណត់ឱ្យស្ថិតក្នុងកម្រិតចំនួន ២០ ៨៣៩ប៊ីលានរៀល (ប្រមាណ ៥ ១២៦លានដុល្លារអាម៉េរិក) ត្រូវជា១៥,៨៧% នៃ ផ.ស.ស. គឺកើនឡើង៩% ធៀបនឹងច្បាប់ថវិកា ឆ្នាំ២០២២។ ចំពោះ ចំណាយមូលធនថវិកាថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ១៥ ៧៦៤ប៊ីលានរៀល (ប្រមាណ ៣ ៨៧៧លានដុល្លារអាម៉េរិក) មានសមាមាត្រស្មើនឹង៤៣,១% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា១២,០១% នៃ ផ.ស.ស. កើនឡើង១៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២ ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល(២០២២-២០២៤) ជាពិសេសគឺការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។

សម្រាប់ឆ្នាំ២០២៣ រាជរដ្ឋាភិបាលគ្រោងធ្វើការបោះផ្សាយមូលបត្ររដ្ឋចំនួន ៨១៣ប៊ីលានរៀល សមមូលនឹងប្រមាណ ២០០លានដុល្លាអាម៉េរិក ព្រមទាំងកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍ ចំនួន ១ ៧០០លានអេសដេអ៊ែ គឺកើនឡើងចំនួន ១០០លានអេសដេអ៊ែ ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។

គ. គម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៣

ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង-ស្រុក ត្រូវបានគ្រោងចំនួន ២ ៦០៣ ប៊ីលានរៀល (ប្រមាណ ៦៤០លានដុល្លារអាម៉េរិក) មានសមាមាត្រស្មើនឹង៩,២% នៃចំណូលចរន្តថវិការដ្ឋ ត្រូវជា១,៩៨% នៃ ផ.ស.ស. មានការកើនឡើង២២,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។

ចំណាយសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងចំនួន ៤ ០៦២ប៊ីលានរៀល (ប្រមាណ ៩៩៩លានដុល្លារអាម៉េរិក) មានសមាមាត្រស្មើនឹង១០,៤% នៃចំណាយថវិការដ្ឋសរុប ត្រូវជា៣,០៩% នៃ ផ.ស.ស. កើនឡើង១៩,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២។

ឃ. តុល្យភាពរួមនៃថវិកាឆ្នាំ២០២៣

នៅក្នុងក្របខ័ណ្ឌថវិកាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ៣,៩៩% នៃ ផ.ស.ស. នៅឆ្នាំ២០២៣ ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២ ដែលមានទំហំ២,៨៦% នៃ ផ.ស.ស. ដែលអាចបំពេញតម្រូវការចំណាយ ទាំងចំណាយចរន្តនិងចំណាយវិនិយោគសាធារណៈ។

ថវិកាឆ្នាំ២០២៣ ត្រូវបានគិតគូរនិងរៀបចំឡើងក្នុងបរិការណ៍នៃការបន្តស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ថិតនៅលើគន្លងនៃកំណើនខ្ពស់និងរស់រវើកឡើងវិញ តាមគន្លងប្រក្រតីភាពថ្មីក្នុងការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ព្រមទាំងការបន្តរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងលំនឹងនៃសង្គម-សេដ្ឋកិច្ច ក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់នៅក្នុង «យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤» និង «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣» ជាពិសេស វិធានការអន្តរាគមន៍ដែលត្រូវបានដាក់ចេញក្នុង «ក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣» ក្នុងខណៈដែលរាជរដ្ឋាភិបាលក៏មានតម្រូវការចាំបាច់ក្នុងការតម្រង់ការប្រើប្រាស់ធនធានឆ្ពោះទៅអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗនៅឆ្នាំ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ ដែលមានជាអាទិ៍៖ ការដំឡើងបៀវត្សជូនមន្ត្រីរាជការ, ការដំឡើងប្រាក់សោធនជូននិវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាអតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ជាពិសេសការកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់និងថ្មី, ការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ១និងក្រ២) និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា, ការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា, ការបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម, កម្មវិធីអន្តរាគមន៍លើផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ព្រមទាំងការអនុវត្តគម្រោងអភិវឌ្ឍន៍តំបន់រុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង, និងការត្រៀមដោះស្រាយថវិកាសម្រាប់អគ្គិសនីកម្ពុជា ដើម្បីធានាស្ថិរភាពថ្លៃអគ្គិសនីកុំឱ្យលើសកម្រិតថ្លៃអនុវត្តបច្ចុប្បន្នជូនប្រជាពលរដ្ឋប្រើប្រាស់, និងជាពិសេសគឺ ការធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ព្រមទាំងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣។

ថវិកាឆ្នាំ២០២៣ បានដាក់ចេញនូវគោលដៅច្បាស់លាស់និងប្រាកដនិយម ដើម្បីរក្សាឱ្យបាននូវតុល្យភាពថវិកា ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម ស្របជាមួយនឹងការតម្រង់ទិស ក៏ដូចជាការផ្តល់អាទិភាពខ្ពស់បំផុតដល់តម្រូវការចំណាយចាំបាច់ទាំងឡាយនៅក្នុងឆ្នាំ២០២៣។ ថវិកាឆ្នាំ២០២៣ អាចត្រូវបានសន្និដ្ឋានថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងហានិភ័យផងទាំងពួង ទាំងក្នុងនិងក្រៅប្រទេស សំដៅបន្តការពារអាយុជីវិត លើកកម្ពស់នូវជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងស្តារនិងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជាទន្ទឹមនឹងការរៀនរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ហើយអាចប្រសិទ្ធនាមបានថាជា *«ថវិកាវិត្តារកម្មចំគោលដៅ ដោយផ្តល់អាទិភាពទី១ ដល់ "មនុស្ស" ពិសេសលើសុខភាព ជីវភាព និងសមធម៌ ព្រមជាមួយនឹងអាទិភាពនៃការបន្តជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចស្របតាម "ក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីថ្មីសម្រាប់ឆ្នាំ២០២១-២០២៣" ក៏ដូចជាកិច្ចប្រឹងប្រែងសម្រេចឱ្យបានជាអតិបរមានូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣»*។

ក្នុងន័យនេះ រាជរដ្ឋាភិបាលអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ សូមផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់ប្រទេសជាតិ ដោយឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិនិងប្រជាជនជាធំ ដើម្បីរួមគ្នាយកឈ្នះលើបញ្ហាប្រឈម ហានិភ័យ និងឧបសគ្គទាំងឡាយ សំដៅនាំនាវាកម្ពុជាឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងយុត្តិធម៌សង្គម ក្រោមម្លប់នៃសុខសន្តិភាពដ៏ត្រជាក់ត្រជុំនិងយូរអង្វែង។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងជា ៥ជំពូក និង១៤មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ ជាលទ្ធផល ចំណូលថវិការដ្ឋ (ថវិកាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) អនុវត្តបានចំនួន **៣១ ២៥៤ ៦៧៣លានរៀល** (ប្រមាណ ៧ ៦៨៨លានដុល្លារអាម៉េរិក) ត្រូវជា២៨,២៨% នៃ ផ.ស.ស. ស្មើនឹង ១០៤,៥% នៃច្បាប់ថវិកាឆ្នាំ២០២១។ ការអនុវត្តចំណាយថវិការដ្ឋបានចំនួន **៣៥ ៩៥០ ៤៥៧,១លានរៀល** (ប្រមាណ ៨ ៨៤៣លានដុល្លារអាម៉េរិក) ត្រូវជា៣២,៥៣% នៃ ផ.ស.ស. ហើយស្មើនឹង៩៨,១% នៃច្បាប់ថវិកាឆ្នាំ២០២១។ ជាមួយគ្នានេះ អតិរេកនៃថវិកាចរន្តសម្រេចបានត្រឹមតែ ៩៧២,៩ប៊ីលានរៀល ស្មើនឹង ០,៨៨% នៃ ផ.ស.ស. ខណៈដែលឱនភាពថវិកាថ្នាក់ជាតិបានកើនឡើងដល់ ១០ ២៧៦,៦ប៊ីលានរៀល ស្មើនឹង ៩,៣% នៃ ផ.ស.ស. ដែលតម្រូវឱ្យប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាលប្រមាណ ៥ ០៧៥,៤ប៊ីលានរៀល ស្មើនឹង ៤,៥៩% នៃផ.ស.ស.។

ថវិកាឆ្នាំ២០២១ ត្រូវបានគិតគូររៀបចំនិងអនុវត្តក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ដើម្បីតម្រង់ការប្រើប្រាស់ធនធាន សម្រាប់ទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការរក្សាលំនឹងសង្គម-សេដ្ឋកិច្ចកម្ពុជា និងជីវភាពរបស់ប្រជាជន ព្រមទាំងការស្តារនិងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ក៏ដូចជាដើម្បីសម្រេចនូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ជាពិសេសការជំរុញការអនុវត្តកិច្ចការកែទម្រង់គ្រប់វិស័យក្នុងឆ្នាំ២០២១ ដែលជាឆ្នាំពាក់កណ្តាលអាណត្តិរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី៦។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌថវិកាឆ្នាំ២០២១ ក៏មានគោលដៅបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយដែលសម្រេចបានក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមក ព្រមជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីជម្នះនិងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងទៀតទាំងក្នុងនិងក្រៅប្រទេស ដើម្បីកម្ពុជាអាចឈររឹងមាំនិងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួននៅពេលបច្ចុប្បន្ននិងទៅអនាគត។

ថវិកាឆ្នាំ២០២១ អាចចាត់ទុកជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងការរក្សាលំនឹងសេដ្ឋកិច្ចនិងជីវភាពប្រជាជន ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ដ៏កាចសាហាវ ព្រមទាំងបម្រើដល់ការស្តារសេដ្ឋកិច្ចនិងជំរុញកំណើនជាបណ្តើរៗឡើងវិញ។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០២១ ក៏បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការខិតខំបង្កើនប្រសិទ្ធភាពនិងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងវិធានការរដ្ឋបាលនិងវិធានការគោលនយោបាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣ ទន្ទឹមនឹងការបន្តគោលនយោបាយបន្ធូរបន្ថយនិងអនុគ្រោះពន្ធ ដើម្បីទ្រទ្រង់ដំណើរការអាជីវកម្ម ដែលប៉ះពាល់ដោយសារការអូសបន្លាយនៃស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩។ ក្នុងន័យនេះ ថវិកាឆ្នាំ២០២១ ត្រូវបានសន្និដ្ឋានថាជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព ដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងហានិភ័យផងទាំងពួង ទាំងក្នុងនិងក្រៅប្រទេស ហើយត្រូវបានប្រសិទ្ធនាមថាជា *«ថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ច ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជាជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន»*។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានរៀបចំឡើងជា៣ជំពូក និង២២មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៣-២០២៥

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៣-២០២៥ ត្រូវបានរៀបចំឡើងដោយផ្អែកលើស្មារតីនិងខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ដោយគិតគូរដល់កត្តាជាចម្បងនិងស្ថានភាពជាក់ស្តែងសំខាន់ពីរគឺ ទី១-ការបង្ហាញពីទិន្នន័យនៃគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ន ដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង ផ.យ.អ.ជ. ២០១៩-២០២៣ និង ទី២-តម្រូវការចំណាយសរុបសម្រាប់ការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ប្រមាណ ២៣ ៥០០លានដុល្លារអាមេរិក)។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២៣-២០២៥ បានដាក់បញ្ចូលគ្នានូវគម្រោងកំពុងដំណើរការ ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ដែលជាគម្រោងស្នើសុំថ្មីត្រូវអនុវត្តក្នុងដំណាក់កាល ក.វ.ស.។ ចំពោះសេចក្តីព្រាង ក.វ.ស. ២០២៣-២០២៥ នេះ មានគម្រោងសរុបចំនួន ៦៦៣ ក្នុងនោះ ១៨៩ ជាគម្រោងកំពុងដំណើរការ ដែលត្រូវការទុនចំនួន ៥ ១០៦លានដុល្លារអាម៉េរិក និង ៤៧៤ ជាគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ឬជាគម្រោងថ្មី ដែលត្រូវការទុនចំនួន ៤ ១១៥លានដុល្លារអាម៉េរិក។ បរិមាណទុនសរុបតាមឆ្នាំ របស់ ក.វ.ស. ២០២៣-២០២៥ រួមមាន ឆ្នាំ២០២៣ ចំនួន ២ ៩៦៥លានដុល្លារអាម៉េរិក, ឆ្នាំ២០២៤ ចំនួន ៣ ០៤១លានដុល្លារអាម៉េរិក, និង ឆ្នាំ២០២៥ ចំនួន ៣ ២១៥លានដុល្លារអាម៉េរិក។ ដូច្នេះ បរិមាណទុនសរុបនៃ ក.វ.ស. ៣ឆ្នាំរំកិល ២០២៣-២០២៥ មានចំនួន ៩ ២២១លានដុល្លារអាម៉េរិក ក្នុងនោះ បរិមាណទុនដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍរួចហើយ មានចំនួន ៦ ៩៧៧,១លានដុល្លារអាម៉េរិក (ក្នុងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា មានចំនួន ៣៨៧,៥លានដុល្លារអាម៉េរិក និងពីដៃគូអភិវឌ្ឍ មានចំនួន ៦ ៥៨៩,៦លានដុល្លារអាម៉េរិក) និងត្រូវការទុនបន្ថែមចំនួន ២ ២៤៣,៩លានដុល្លារអាម៉េរិក។

ការវិភាជទុនដល់គម្រោងនានារបស់ ក.វ.ស. ៣ឆ្នាំរំកិល ២០២៣-២០២៥ ទៅតាមវិស័យនីមួយៗ ត្រូវបានកំណត់ : វិស័យសង្គមកិច្ច(១៣,៤%) វិស័យសេដ្ឋកិច្ច(៤៣,៦%) វិស័យហេដ្ឋារចនាសម្ព័ន្ធ(៣៧,៤%) និង វិស័យសេវាកម្មនិងកម្មវិធីអន្តរវិស័យ(៥,៦%)។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៣-២០២៥ ត្រូវបានរៀបចំឡើងជា ៥ជំពូក និងមានបញ្ជីតារាង១២ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ៤-បញ្ហាផ្សេងៗ

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ៖

៤.១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មនៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន។

៤.២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក) នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

៤.៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- រាជរដ្ឋាភិបាលនឹងសហការជាមួយដៃគូអភិវឌ្ឍ ជំរុញគម្រោងសាងសង់ផ្លូវល្បឿនលឿនតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ក្រុងបាវិត ខេត្តស្វាយរៀង ឱ្យបានឆាប់រហ័ស

- រាជរដ្ឋាភិបាលបន្តលើកទឹកចិត្តដល់វិស័យឯកជនដែលវិនិយោគលើផលិតកម្មស្រូវ-អង្ករនៅក្នុងប្រទេសកម្ពុជាឱ្យបានច្រើនជាងមុន ដើម្បីសម្រេចចក្ខុវិស័យនៃការនាំចេញអង្ករឱ្យបានមួយលានតោនរបស់កម្ពុជា ស្របតាមគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពង្រឹងការអនុវត្តតួនាទីរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់, ស្មៀនឃុំ សង្កាត់, ប្រធានភូមិ, ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងប្រធានមណ្ឌលសុខភាពឃុំ សង្កាត់ ដែលជាមន្ត្រីបង្គោលនៅមូលដ្ឋានឃុំ សង្កាត់ ក្នុងការអនុវត្តភារកិច្ចផ្តល់សេវាសាធារណៈដោយផ្ទាល់និងល្អប្រសើរជូនប្រជាពលរដ្ឋ

-រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមខ្លួនក្នុងការពង្រឹងការរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ ក្នុងខណៈពេលដែលព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤០ និងទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធ នាខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខនេះ

- រាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ជំហរដាច់ខាតថ្កោលទោសចំពោះជនជ្រុលនិយមនិងជនក្បត់ជាតិ ដែលបានប្រមាថលើ អង្គព្រះមហាក្សត្រជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា ដែលការប្រមាថនេះគឺជាទង្វើបំពានយ៉ាងធ្ងន់ធ្ងរលើមាត្រា៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា «អង្គព្រះមហាក្សត្រមិនអាចមាននរណាមករំលោភបំពានបានឡើយ»

- សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងបន្តចុះជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមបណ្តារាជធានី-ខេត្ត និងនាំយកស្រូវពូជនិងស្បៀងអាហារដើម្បីចែកជូនប្រជាពលរដ្ឋដែលបាននិងកំពុងរងគ្រោះដោយសារគ្រោះទឹកជំនន់

- សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដែលបានយកចិត្តទុកដាក់និងជួយឧបត្ថម្ភនូវអាវរងាជូនដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលបាននិងកំពុងឈរជើងនៅតាមព្រំដែនគោកនិងដែនដីកោះនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានកោតសរសើរនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានរក្សាសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១និង២០នាទី។

ថ្ងៃសុក្រ ៤កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២